# គំរោងការបំផ្លាញព្រះពុទ្ធសាសនារបស់អង្គការគ្រិស្តសាសនា

*សិក្សាប្រៀបធៀបហេតុការណ៍បច្ចុប្បន្ននៅក្នុងប្រទេសកម្ពុជា*

**និង បទពិសោធន៏នៅប្រទេសថៃ**

*រៀបរៀង និង បកប្រែដោយ* ***ជោទានោភិក្ខុ***

*ចាប់តាំងពីពេលដែលអង្គការសហប្រជាជាតិបានចូលមកជួយរៀបចំសន្តិភាពនៅប្រទេសកម្ពុជាក្នុងឆ្នាំ១៩៩៣កន្លងមក ដល់សព្វថ្ងៃ មានអង្គការគ្រិស្តសាសនាជាច្រើនបានជ្រៀតចូលមកជាមួយក្នុងនាមជាអង្គការសង្គ្រោះជនក្រីក្រ ក្មេងកំព្រា ជនពិការ និងសង្គមសង្គ្រោះផ្សេងៗ។ មកដល់បច្ចុប្បន្នគ្រាន់តែក្នុងទីក្រុងភ្នំពេញមានព្រះវិហារនិងការិយាល័យគ្រីស្តសាសនាចំនួនជាង៣០០។ ដែលគោលការណ៏ធំរបស់ពួកគេ គឺដើម្បីទាក់ទាញប្រជាជនខ្មែរដែលភាគច្រើនជាពុទ្ធសាសនិកជន ឲ្យលះបង់សាសនាដើមរបស់ខ្លួន ចូលមកកាន់សាសនាគ្រិស្ត។ តើគោលបំណងនិងវិធានការរបស់អង្គការគ្រិស្តសាសនានេះ មានផលល្អឬផលអាក្រក់ចំពោះមាតុភូមិនិងប្រជាជនខ្មែរយ៉ាងណា? ។*

**ករណីដែលត្រូវសិក្សា**

- *មានការដុតបំផ្លាញវិហារគ្រិស្តនៅគោកព្រីងកាលពី២៨ កក្កដា ២០០៣*
- *ការរំខានភាពស្ងប់ស្ងាត់របស់ពួកជិះកង់ផ្សាយសាសនាក្មេងៗនិកាយមោម៉ង*
- *ការនិយាយថាព្រះពុទ្ធគ្រាន់តែជាអ្នកណែនាំឲ្យគេស្គាល់ព្រះយេស៊ូរបស់លោកភាព យន្ត តាមវិទ្យុអាស៊ីសេរី កាលពីថ្ងៃទី៣ សីហា ២០០៥*

**បញ្ហាដែលអាចកើតឡើងនាពេលអនាគត**

- *ការកំហុកចូលយ៉ាងខ្លាំងប្រកបដោយមហិច្ឆតារបស់មេដឹកនាំសាសនាគ្រិស្តនៅប្រទេសកម្ពុជាក្នុងការទាញឲ្យខ្មែរប្តូរសាសនារបស់ខ្លួន ជាការធានានូវសន្តិភាពនិងការរីកចំរើនសំរាប់ខ្មែរ ឬគ្រាន់តែអំណាចលោភលន់របស់អង្គការគ្រិស្តសាសនាពិភពលោក?*

- គ្រិស្តសាសនា ជានិច្ចជាកាលរមែងភ្ជាប់ខ្លួនទៅនឹងនយោបាយដើម្បីពង្រឹងអង្គការរបស់ខ្លួន ករណីសិក្សាដូចជាកោះទីម៉ និងប្រទេសហ្វីលីពីន ជាដើម។
- វប្បធម៌កម្ពុជានិងព្រះពុទ្ធសាសនាបានរលាយចូលគ្នាតែមួយ ថ្ងៃណាមួយប្រសិនបើពុទ្ធសាសនិកជនក្លាយជាគ្រិស្តសាសនិកជនទាំងអស់ អត្តសញ្ញាណជាខ្មែរនឹងត្រូវបាត់បង់ ទោះបីជាអង្គការគ្រីស្តជាច្រើនព្យាយាមធ្វើឧបាយចាត់រៀបមង្គលការធ្វើបុណ្យទាន មានភ្ជុំបិណ្ឌជាដើម ជាលក្ខណៈខ្មែរក៏ដោយ ។

## មតិអ្នកប្រាជ្ញខ្មែរ

ព្រះតេជគុណបណ្ឌិតហុក សាវណ្ណ ជាអ្នកប្រាជ្ញខ្មែរមួយព្រះអង្គដែលបានយកចិត្តទុកដាក់បញ្ហាសង្គមខ្មែរ ក៏ដូចជាបញ្ហាសាសនាយ៉ាងខ្លាំង។ ព្រះអង្គបានមានថេរដីកាថា ជាការចំឡែកខ្លាំងណាស់សំរាប់ការរីកដុះដាលវិហារនិងការិយាល័យផ្សព្វផ្សាយគ្រិស្តសាសនាដ៏ច្រើនលើសលប់ បើប្រៀបធៀបទៅនឹងសាវ័ករបស់ខ្លួនដែលមានត្រឹមតែ ៥០១១៩នាក់។ នៅទូទាំងប្រទេសមានវិហារ១៧០ និងទីស្នាក់ការ៧៣០។ មិនតែប៉ុណ្ណោះ នៅមានសាលារៀនដែលគ្រប់គ្រងដោយអង្គផ្សាយសាសនាគ្រិស្តប្រហែល១១០។ បើនិយាយតែក្នុងទីក្រុងភ្នំពេញវិញ វត្តព្រះពុទ្ធសាសនាមានតែ៨៥វត្ត តែមានទីស្នាក់ការនិងព្រះវិហារគ្រិស្តសាសនាដល់ទៅ៣០០កន្លែង។ ព្រះអង្គក៏បានបន្ថែមទៀតថា ពីដើមមានរដ្ឋលេខាធិការតែម្នាក់គ្រប់គ្រងមើលការខុសត្រូវទាំងអស់ តែបច្ចុប្បន្នមានតំណាងគ្រប់សាសនាទៅហើយ ដែលជាហេតុធ្វើឱ្យមានការកសាងវិហារ ទាំងគ្រិស្តនិងឥស្លាមច្រើនលើសលប់ បើប្រៀបធៀបទៅនឹងសាវ័ករបស់ខ្លួន។ នៅប្រទេសប្រជាធិបតេយ្យ ដូចជាសហរដ្ឋអាមេរិកនិងកាណាដា ជាពិសេសប្រជាជនខ្មែរយើង សុំច្បាប់កសាងវត្តអារាមបានលុះត្រាតែឆ្លងកាត់តាមរយៈសមាគម ហើយសមាគមនោះត្រូវតែមានសមាជិកច្រើនគ្រប់គ្រាន់ល្មមទើបអាចកសាងវត្តបាន។ យើយមិនអាចកសាងវត្តបានគ្រប់ទីកន្លែងឲ្យតែមានលុយដូចដែលគ្រិស្ត

សាសនាកសាងវិហារភាត់រាយពាសពេញស្រុកខ្មែរនោះទេ។ ម្យ៉ាងទៀត គ្រិស្តសាសនារមែងទាក់ទាញពុទ្ធបរិស័ទខ្មែរ ដោយធ្វើអំណោយទានមានបាយ នំ ចំណី សំលៀកបំពាក់និងសំពត់ខោអាវជាដើម ដែលអំណោយទាននេះ មិនមានភាពបរិសុទ្ធទាល់តែសោះ ប្រៀបដូចនឹងមនុស្សម្នាក់យកនុយទៅដាក់ផ្លែសន្ទូច ហើយនិយាយថាខ្លួនធ្វើទានដាក់នុយឲ្យត្រីស៊ីដូច្នោះ ។

# បទពិសោធន៏របស់ប្រទេសថៃ

បកប្រែពីភាសាសៀម

*ភាគ ១ (ទាំងសងខាង)*

*ព្រះសោភណគុណាជន រ:បែប (រៀបរៀង)*

- និកាយរ៉ូម៉ាំងកាតូលិក ត្រូវការឲ្យប្រទេសថៃជាប្រទេសគ្រឹស្តដោយប្រើគ្រប់វិធីបែបដូចជា

១. ទាញស្តេចព្រះនារាយណ៏ឲ្យចូលគ្រឹស្តសាសនា

២. រដ្ឋកាលទី៣ គ្រូគង្វាលកាតុលិក តែងសៀវភៅជេរនិងប្រមាថព្រះពុទ្ធសាសនាមាន៤៥២ រហូតដល់មានការបិទមិនឲ្យផ្សព្វផ្សាយ

៣. ព.ស.២៥០១ បោះពុម្ពសៀវភៅបុច្ឆាវិសជ្ជនាថែមទៀត ហើយរដ្ឋបាលថៃធ្លាប់ជួយសាងព្រះវិហារគ្រឹស្តនិងថវិកាឧបត្ថម្ភ រហូតដល់ប្រជាជនក្រោកឡើងប្រឆាំង ។

៤. ព.ស.២៥០៨ មានការតាំងឈ្មោះអ្នកបួសរបស់គេដូចគ្នាបេះបិតនឹងព្រះពុទ្ធសាសនា ដូចជាសម្តេចព្រះសង្ឃរាជ ព្រះភិក្ខុ សាមណេរ ដូនជី។ មានការហៅមកសាកសួរឲ្យកែប្រែដោយរដ្ឋបាល តែក៏នៅមានការប្រើដដែល ។

<u>គោលបំណងការវាយបកនេះគឺ</u>

១. ដើម្បីវាយបកចំពោះការប្រជុំខោនស៊ីលវ៉ាតិកាន់ទីពីរ ១៩៦២-៦៤ (Second Vatican Council 1962-64) បានដាក់របៀបថ្មី ហៅថា ដាយអ៊ីឡូក់ (Dialogue) វិធីចូលទៅទាញយកគោលធម៌ព្រះពុទ្ធសាសនាធ្វើជាធម៌របស់ខ្លួន។ ការធ្វើដោយសំងាត់គឺ ចូលទៅធ្វើកម្មវិធីសង្គមសង្គ្រោះហើយជ្រៀតជ្រែកហាមមិនឲ្យមានការរៀនការសិក្សាព្រះពុទ្ធចរិយធម៌នៅតាមសាលារៀន ។

២. ឯកសារជាច្រើនដែលមិនសមហេតុផល និងបំផ្លាញព្រះពុទ្ធសាសនាគឺ

២.១. ព្រះពុទ្ធគ្រាន់តែជាបកាសិតរបស់ព្រះអាទិទេព ដែលបានប្រគល់ធម៌មួយផ្នែកមកព្រះពុទ្ធ ដើម្បីត្រៀមទទួលព្រះយេស៊ូ ។

២.២. ព្រះធម៌ដែលត្រាស់ដឹងកើតពីការប្រទានឲ្យរបស់ព្រះអាទិទេពតិចតួចប៉ុណ្ណោះ តែដែលប្រទានឲ្យច្រើនគឺព្រះយេស៊ូ ។

២.៣. មានការបំផ្លាញព្រះធម៌នៅគ្រប់រូបភាព ដូចជា

២.៣.១. យកព្រះធម៌ទៅប្រើក្នុងសាសនារបស់គេ ដោយមិនអាងថាជារបស់ព្រះពុទ្ធសាសនាឡើយ ។

២.៣.២. នាំព្រះធម៌ទៅបំផ្លើសដោយអធិប្បាយថា អរិយសច្ច៤ ធម៌អនត្តា បដិច្ចសមុប្បាទ មានរួចរាល់ហើយក្នុងគម្ពីរគ្រីស្តសាសនា ។

២.៣.៣. លោកុត្តរធម៌ក្នុងសាសនាគ្រីស្តក៏មាន ហើយព្រះនិព្វានគឺឋានសួគ៌ានោះឯង ។

២.៣.៤. បដិសេដធ៏ការធ្វើល្អតាមគោលត្រៃសិក្ខា ថាមិនបាន ផលអ្វីឡើយ ផលដែលបានពិតប្រាកដគឺព្រះស្រី អារិយមេត្រីដែលជាព្រះយេស៊ូនោះឯង ។

២.៣.៥. ព្រះពុទ្ធសាសនារលាយអស់ទៅហើយកាលព.ស.២៥០ ហើយយុគសព្វថ្ងៃគឺយុគព្រះយេស៊ូ ។

- *សំណូមពរគួរបញ្ឈប់ការមើលងាយព្រះរតនត្រ័យ*

ការដែលគ្រីស្តសាសនាធ្វើដូច្នេះ ជាការដាស់សតិពុទ្ធិសាសនិកជនឲ្យប្រុងប្រយត្ន័ ដូចជា

១. ការមកជាមិត្តជិតនឹងយើងសិន រួចកំចាត់ជាក្រោយ

២. អ្នកបួសក្នុងគ្រីស្តសាសនាកំពុងកសាងអមិត្តទៀតហើយ

៣. ដើម្បីឲ្យយើងស្គាល់ច្បាស់តើធ្វើការឲ្យវ៉ាតិកាន់ដូចជាកីរតិប៊ុនជឿ, ចន លោអានណា, ជួប សម័យ, រក្ស បំរុងត្រកូល, ង៉ន រឿនចានជាដើម ត្រូវឈប់ការប្រព្រឹត្តដូច្នោះ ។

៤. អំពាវនាវឲ្យក្រុងវ៉ាតិកាន់មជ្ឈបប់ការប្រើប្រាស់វិធីការទាំងនោះក្នុងប្រទេសថៃ

*ទស្សនវិជ្ជាការធ្វើការរបស់គ្រីស្តសាសនាគឺ*

១. យកដើមឫស្សីកាត់ដើមឫស្សី ដូចដែលអ្នកធ្វើការទាំងអស់គឺជនជាតិថៃ

២. ជ្រាបយ៉ាងសំងាត់ថា ផែនការនឹងធ្វើឲ្យប្រទេសថៃជាប្រទេសគ្រីស្តក្នុង ឆ្នាំ២០០០ ដោយឲ្យប្រទេសថៃជាមជ្ឈមណ្ឌលគ្រីស្តសាសនានៅ អាស៊ីអាគ្នេយ៏ ។

៣. ដោយមានទុនមានលុយច្រើន ទើបទាញឲ្យមនុស្សពូកែៗរៀនបានខ្ពង់ខ្ពស់ ហូតដល់នៅក្នុងប្រទេស មានអ្នកកាន់គ្រីស្តសាសនាមិនប៉ុន្មាន ភាគរយផង តែអាចហាមមិនឲ្យយកកម្មវិធីសីលធម៌ព្រះពុទ្ធសាសនាទៅ បង្រៀនក្នុងសាលារដ្ឋបាន ។

ដើម្បីការយោគយល់គ្នា(ព្រះសោភណគុណាភរ វត្តបវរនិវេស) បានមានថេរដីកាថា

- គ្រីស្តសាសនាជាទេវនិយម ព្រះពុទ្ធសាសនាជាអទេវនិយម តែមើលឃើញទេវតា មារព្រហ្មទាំងអស់ជាមិត្តរួមលោក តាមកម្មរៀងៗខ្លួន ទើបគួររស់នៅរួមគ្នា ដោយសន្តិភាព ។

ការបង្រៀនរបស់ព្រះពុទ្ធអង្គមានដូចជា

១. <u>បដិរូប</u> ពីជំនឿអរូបិយ៍ទៅជាជំនឿមានហេតុផល

២. <u>បដិវត្តន៍</u> ជំនឿជ្រុលលើអាទិទេពទៅជាជំនឿបែបប្រជាធិបតេយ្យ

៣. <u>ការប្រកាសគោលធម៌ថ្មី</u>ដូចជា កម្មផល អនត្តា បដិច្ចសមុប្បាទ និង អរិយសច្ច៤ ជាដើម ។

៤. <u>រក្សាយកសុភាសិតល្អៗពីអ្នកប្រាជ្ញផ្សេងៗ</u> បើពោលតាមសេចក្តីពិតនិង ប្រយោជន៍ ហើយប្រាប់ប្រភពច្បាស់លាស់ មិនមានការលួចសិទ្ធិខាង បញ្ញាឡើយ ។

- គោលដៅការប្រកាសសាសនាគឺដើម្បីប្រយោជន៍និងសេចក្តីសុខរបស់សត្វលោក (ចរថ ភិក្ខវេ ចារិកំ ពហុជនហិតាយ ពហុជនសុខាយ......) ។

មូលដ្ឋានខុសគ្នាចំពោះគ្រីស្តសាសនា និង ព្រះពុទ្ធសាសនា មានដូចជា

<u>ទស្សនៈចំពោះលោកនិងជីវិតរបស់គ្រីស្តសាសនា</u>

១. ពិភពលោក ជីវិត និងសព្វសត្វទាំងអស់កើតពីការកសាងរបស់ព្រះអាទិទេព

២.        ទទួលស្គាល់ឋានៈមនុស្សល្អមានចំពោះតែពួកគ្រីស្តសាសនិក តែក្រៅពីនោះសុទ្ធតែពួកទមិឡ អត្ថិរតិយ្យ តែគេអាចជាមនុស្សល្អបាន បើមករាប់អានគ្រីស្តសាសនា ។

៣.      សំគាល់សាសតាសាសនាដទៃថាជាសាតាន ជាសត្រូវរបស់ព្រះអាទិទេពដែលត្រូវបំផ្លាញ ។

ព្រឹត្តិប័ត្រប្រកាសរបស់វ៉ាតិកាន់ទំព័រទី៧-៨ សរសេរថា អ្នកចូរទៅធ្វើឲ្យប្រជាជាតិទាំងអស់ឲ្យជាសាវ័ករបស់យេស៊ូ។ ការប្រកាសដំណឹងល្អនេះក៏ដើម្បីផ្លាស់ប្តូរពួកគេឲ្យជាគ្រីស្តសាសនិកជន ។

និកាយកាតូលិកចូលមកប្រកាសសាសនាក្នុងប្រទេសថៃ ក្នុងរាជកាលនារាយមហារាជកាលពី៣០០ឆ្នាំមុន ដោយប្រើឧបាយផ្សេងៗទាំងផ្នែកសេដ្ឋកិច្ច ការសិក្សា នយោបាយ និងយោធា ។

រាជសម័យព្រះនាងក្លោចៅយូហួ ប៉ាស្តើគ្រីស្តសាសនារ៉ូម៉ាំងកាតូលិកបានបោះពុម្ពសៀវភៅឈ្មោះ បុច្ឆាវិសជ្ជនា មាន២៣១ មើលងាយមើលថោកចំពោះព្រះរតនត្រ័យ ។ មតិសង្គាយនាវ៉ាតិកាន់ ចុះក្នុងព្រឹត្តិបត្រ ក្បាលទី១០ ទំព័រទី២៤-២៥ សរសេរថា

១. ការងាររបស់វ៉ាតិកាន់ត្រូវកំណត់ឲ្យយើងធ្វើការយ៉ាងជិតស្និទ្ធជាមួយព្រះពុទ្ធសាសនា ។

២. កិច្ចការសង្គមជួយសង្គ្រោះជាតិនិងប្រជាជន ត្រូវធ្វើការយ៉ាងជិតស្និទ្ធជាមួយព្រះភិក្ខុសង្ឃ តែការងារដែលបានប្រយោជន៍ខ្ពស់បំផុត គឺការងារដែលពួកអ្នកចេះដឹងរបស់យើងចាត់ធ្វើតម្រាគម្ពីរព្រះពុទ្ធសាសនាឲ្យជារបស់យើង។ (សព្វថ្ងៃនៅប្រទេសថៃមានគម្ពីរប៊ីបសរសេរជាភាសាបាលីរួចទៅហើយ) ។

ការធ្វើដាយអ៊ីឡុក់បែបរ៉ូម៉ាំងកាតូលិក មានលក្ខណៈដូចគ្នានឹងការប្រើវិធីស្រូបយកព្រះពុទ្ធសាសនារបស់**សង្ឃរាចារ្យ**ក្នុងប្រទេសឥណ្ឌា ដោយដាក់តំណែងព្រះពុទ្ធជាម្ចាស់

ទៅជាអវតាមួយរបស់ព្រះវិស្ណុ ព្រះពុទ្ធសាសនាក៏រលាយពីឥណ្ឌា ។

តមកពួកព្រាហ្មបានយកនិកាយតន្ត្រៈមកដាក់ក្នុងព្រះពុទ្ធសាសនា រហូតដល់មើល មិនយល់ថាអ្វីគឺជាធម៌ពិតរបស់ព្រះពុទ្ធជាម្ចាស់។ នៅសតវត្សទី១៧ ពួកឥស្លាមតឺក បាន ចូលមកបំផ្លាញសកលវិទ្យាល័យ វត្តអារាម និងធ្វើគត់ព្រះសង្ឃ រហូតដល់ធ្វើឲ្យឥណ្ឌា គ្មានព្រះពុទ្ធសាសនាដល់ទៅ៨០០ឆ្នាំ។ នេះជាមេរៀនប្រវត្តិសាស្ត្រ ដែលក្រុមគ្រីស្ត សាសនាកាតូលិកបានធ្វើមជ្ឈមណ្ឌលស្រាវជ្រាវសាសនាឥណ្ឌូនៅឥណ្ឌា និង ឥស្លាម នៅប៉ាគីស្ថាន។ ទើបមានឧបាយកលដូចតទៅនេះ :

១.បន្ទាបឋានៈព្រះពុទ្ធមកត្រឹមបកាសកៈរបស់អាទិទេព និងថាព្រះស្រីអារិយមេត្រី ជាព្រះយេស៊ូ នៅក្នុងសៀវភៅដែលសរសេរដោយគ្រូ**គង្វាលម៉ាណាត់** ហើយថាព្រះពុទ្ធ គ្រាន់តែជាអ្នកបំរើរបស់អាទិទេពនិងយេស៊ូតែប៉ុណ្ណោះ ដូចដែលឃ្លាមួយនិយាយថា ព្រះពុទ្ធជាម្ចាស់បានទំនាយទុកថានឹងមានព្រះសេអារ៉ីមកត្រាស់ដឹងបន្ទាប់ពីព្រះអង្គបរិ និព្វានបាន៥០០០ឆ្នាំ ហើយព្រះនឹងស្ដេចយាងមកប្រោសប្រជាជននៅអាស៊ីភាគខាងកើត យុគរបស់ព្រះសេអារិយៈចាប់ផ្ដើមហើយ ចូរនាំគ្នាគោរពជឿតាមដើម្បីស្វែងរកសន្តិភាព និងសេចក្ដីសុខ។ ប៉ាស្ទ័រភីរតិប៊ុន ជឿ ក៏គាំទ្រមតិនេះ ដោយសរសេរថា ព្រះអាទិទេព គឺតួអង្គពិតគ្រប់យ៉ាងកើតពីអាទិទេព ពេលព្រះពុទ្ធបង្រៀនសច្ចភាព សច្ចភាពនោះគឺមក ពីអាទិទេព។ ប៉ាស្ទ័រអេម៉ូលិន សរសេរក្នុងព្រឹត្តបត្របរិទស្សន៍ ច្បាប់ទី៥ ខែឧសភា-សីហា ២៥២៤ទំព័រ២៤ថាយើងអាចទទួលស្គាល់ការត្រាស់ដឹងរបស់ព្រះពុទ្ធជាម្ចាស់ថាជាការបណ្ដាល របស់ព្រះអាទិទេព។ ប៉ាស្ទ័រម៉ាណាត់ ជួបសម័យ ក៏សរសេរគាំទ្រគំនិតនេះក្នុងព្រឹត្តបត្រ ច្បាប់ទី៥ ទំព័រ១០៤ថា ក្នុងយោបល់របស់គ្រីស្តសាសនិក ទ្រឹស្ដីបដិច្ចសមុប្បបាទ ជាគំនិតដ៏ប្រ ពៃរដែលអាទិទេពផ្ដល់ដើម្បីយកមកលាតត្រដាងប្រាប់មនុស្សលោក ។

ការនិយាយដូច្នេះ ស្របទៅនឹងការប្រកាសរបស់វ៉ាតិកានខោនស៊ីលទីពីរ ក្បាលទីពីរ ទំព័រទី៣០ថា អាទិទេពជាប្រភពតែមួយរបស់មនុស្សទាំងពួង ដូច្នេះគ្រប់សាសនាទាំងអស់ត្រូវតែស្ថិតក្រោមឥទ្ធិពលតែមួយ ។

ការធ្វើដូច្នេះអាចប្រៀបធៀបបានថា

- ព្រាហ្មបន្ទាបព្រះពុទ្ធមកត្រឹមអវតារតែគ្រីស្តបន្ទាបមកជាអ្នកប្រកាស(បកាសកៈ)
- ព្រាហ្មយកធម៌ព្រះពុទ្ធអង្គមកដាក់ក្នុងគម្ពីរវេតន្តៈនិងឧបនិស័ទថាជាវាទៈរបស់ព្រះព្រហ្ម គ្រីស្តក៏យកធម៌ព្រះអង្គមកតិះដៀលខ្លះនិងសរសើរខ្លះ រួចនិយាយថាជាការប្រកាសរបស់អាទិទេពមួយអង្គគត់ ។
- ព្រឹត្តិបត្រក្បាលទី១០ ទំព័រ៣៦ និយាយទទួលស្គាល់ថា សច្ចធម៌ដែលមានក្នុងសាសនាទាំងឡាយមានខ្លះគ្រាន់តែជាសច្ចធម៌ដែលមានចែងច្បាស់នៅក្នុងគ្រីស្តសាសនាតែប៉ុណ្ណោះ ។

<u>កំណើតរបស់លោក</u>

ព្រះពុទ្ធជាម្ចាស់ត្រាស់ថាវាជាអចិន្តៃយ៍ ទៅនិយាយអំពីកំណកំណើតរបស់លោកដូចគ្នានិយាយអំពីមេមាន់និងពងមាន់មួយណាកើតមុន?។ រាប់ចាប់តាំងពី**អាភស្សរាព្រហ្ម**ដាច់ឈានមកជាប់នឹងដីនៃលោកមនុស្សក៏មានការវិវឌ្ឍន៍រឿយៗ រហូតដល់មានការរលត់រលាយទៅវិញ ហើយក៏កកើតឡើងវិញទៅតាមច្បាប់ធម្មជាតិរបស់វា។ ការសង្ស័យឬជជែកតែរឿងនេះ ធ្វើឱ្យយើងនៅតែងោកងល់នៅក្នុងអវិជ្ជា ជាហេតុធ្វើឱ្យកើតសេចក្តីទុក្ខ។ ព្រះពុទ្ធអង្គធ្លាប់បដិសេធន៍មកហើយនូវការបេះកសាងលោកសាងមនុស្សរបស់**បរមាត្មន** ក៏ដូចជាអាទិទេពដែរ។ **មហាថេរៈសោភាទេវី**ក្នុងសម័យពុទ្ធកាលក៏ធ្លាប់ឆ្លើយចំពោះសំណួរដែលថា តើរូបកាយនេះនរណា

ជាអ្នកកសាង វាកើតមកពីណា ព្រះមហាថេរៈឆ្លើយយ៉ាងនេះថា រូបកាយនេះកើតមក អំពីហេតុរបស់វា ពេលហេតុរបស់វារលត់ វាក៏រលត់ទៅតាមដែរ ។

ការជឿថាព្រះព្រហ្មសាងលោក ត្រូវបានពន្យល់យ៉ាងច្បាស់ដោយព្រះពុទ្ធជាម្ចាស់ថាជាការជឿអរូបីយ៍ជំនឿ **ដូចមនុស្សខ្វាក់ភ្នែកដែលកំពុងដឹកដៃមនុស្សខ្វាក់ភ្នែកដូចគ្នាដើរជាជួរៗ តាមៗគ្នារហូតមក** ។

## កាសែតទី២ ភាគ១

ការនិយាយពីដើមកំណើតលោកនិងវត្ថុគ្រប់យ៉ាង ជាការបង្កបង្កើតនូវអវិជ្ជា និងមោហៈ ដែលម្នាក់ៗសុទ្ធតែមានហេតុផលរៀងៗខ្លួន ជជែកវែកញែកគ្នាមិនចេះចប់មិនចេះហើយរហូតដល់ឈ្លោះទាស់ទែងគ្នា ឬជីវិតខ្លីស្លាប់អសាបង់ឥតការ ដោយមិនបានធ្វើអំពើកុសលអ្វីសោះ។ ការនិយាយពីអាទិទេពសាងលោក នឹងមានតែសញ្ញាសួរថា **នរណា? ពីណា? ពេលណា? ហេតុអ្វី?** មិនចេះចប់។

**បណ្ឌិតអារិយទេព** អ្នកតែងគម្ពីរសាស្រ្តសាសន៍បានលើកចំណុចមួយចំនួនមកនិយាយថា :

១. បើព្រះយេហូវ៉ាសាងលោកមែន ហេតុម្តេចក៏សាងមារ(សាតាន)មកជាមួយ? ពីមុនមារជាទេព តែក្រោយមកជាមារ។ ព្រះអាទិទេពយេហូវ៉ាមិនដឹង ឬព្រោះតែអវិជ្ជា ឬមួយយ៉ាងណា?។ ហើយអពមង្គលគ្រប់យ៉ាងក្នុងលោកបណ្តាលមកពីមារ ហើយតើនរណាទទួលខុសត្រូវ? ដូចជាមាតាបិតា នាំចោរមកចូលក្នុងផ្ទះ រួចចោរធ្វើទុក្ខបុកម្នេញគ្រប់បែបយ៉ាង តែមាតាបិតានោះចោទកូនទៅវិញ ខ្លួនឯងមិនទទួលខុសត្រូវបែរជាមកផ្តន្ទាដាក់បណ្តាសារឲ្យកូនខ្លួនឯងទៅវិញ ។

២. បើនិយាយអាទិទេពមិនបានសាងមារ ក៏មានន័យថាអាទិទេពមិនបានសាងវត្ថុគ្រប់យ៉ាង នៅក្នុងលោក ហើយបើបណ្ដោយឲ្យមារធ្វើបាបមនុស្សលោក ក៏មានន័យថាអាទិទេពគ្មានអំណាចអ្វីសោះក្នុងការការពារមនុស្សល្អទាំងឡាយ ។

៣. អាទិទេពសាងមនុស្ស ហើយមានសេចក្ដីស្រឡាញ់មនុស្សខ្លាំងណាស់ បើដូច្នោះមែន ហេតុអ្វីកសាងភ័យធម្មជាតិ ជំងឺរាតត្បាត ចំបាំងរាំងដល់ឲ្យមនុស្សលោក?។ បើនិយាយថា អាទិទេពមិនទទួលដឹងឮរឿងទាំងនេះទេ រឿងនេះជារឿងរបស់មនុស្សខ្លួនឯង ក៏មានន័យថា អាទិទេពមិនបានស្រឡាញ់មនុស្សពិតប្រាកដទេ ។

បណ្ឌិតអារិយទេព បានសរុបខ្លីៗថា :

១. ព្រះអាទិទេពសាងលោកពោរពេញទៅដោយ**លោភ**: ព្រោះចូលចិត្តគ្រឿងបូជាយញ្ញប្រណីតៗ ចង់ឲ្យគេជឿ ឲ្យគេគោរពដើរតាមខ្លួន ចង់ឲ្យគេកោតសរសើរស្ញប់ស្ញែងខ្លួន ប្រណិបត្តិខ្លួន។

២. ប្រកបដោយ**ទោស**: ព្រោះជានិច្ចជាកាលសំដែងអាការៈខឹងសំបារយ៉ាងខ្លាំង ដែលខឹងខ្លាំងជាងគេគឺព្រោះព្រះអង្គទំសាងមនុស្សមក ហេតុអ្វីមនុស្សមិនជឿ មិនមានសទ្ធាចំពោះព្រះអង្គ? ហើយបើនរណាមិនគោរពជឿតាមព្រះអង្គទេ ព្រះអង្គនឹងធ្វើឲ្យអ្នកនោះធ្លាក់នរកឬជួបតែភ័យវិបត្តិក្នុងជីវិត។ ហើយបើយើងមើលទៅមារ មិនឃើញមារខឹងហើយដាក់ទោសមនុស្សដូចនេះសោះ នេះជារឿងចំឡែកណាស់ ។

៣. ប្រកបដោយ**មោហ**: ព្រោះកសាងអ្វីគ្រប់យ៉ាងរឿយពឿយទៅ ដោយមិនដឹងថាវត្ថុនោះល្អឬអាក្រក់ ហើយនៅវង្វេងខ្លួនឯងថា មានមេត្តា អាណិតអាសូរនិងស្រឡាញ់ដល់មនុស្ស ហើយទាមទារឲ្យមនុស្សតបស្នងសងគុណខ្លួន ស្រើងអំណាច វង្វេងខ្លួនឯង។

៤.	ព្រះអាទិទេពសាងលោកហើយ តើអាទិទេពមួយណាជាអាទិទេពពិត បើពួកទេវនិយមទាំងឡាយ រមែងអះអាងថាអាទិទេពខ្លួនឯងជាតួអង្គពិត ហើយរបស់អ្នកដទៃក្លែងក្លាយ លោកនេះមានលោកតែមួយ អ្នកកសាងត្រូវតែមានតែមួយ តែវាមិនដូច្នេះទេ សាសនាបូជាអាទិទេពផ្សេងៗបានឈ្លោះនិងវាយប្រហារសំឡាប់រង្គាលគ្នារាប់សតវត្សន៍មកហើយ។

ការលើក មកនេះគ្រាន់តែជាផ្នែកតូចមួយដើម្បីការយោគយល់គ្នាទៅវិញទៅមកតែប៉ុណ្ណោះ មិនមែនជាទស្សនវិស័យរបស់ពុទ្ធសាសនិកជនដែលចង់យកឈ្នះយកចាញ់នោះទេ ។

## ព្រះធម៌ដែលកើតពីអាទិទេពនោះ តើមានភស្តុតាងខាងប្រវត្តិសាស្រ្តទេ?

- អតីតគ្រូគង្វាលសេរី ភួងភិត បានឲ្យសំភាសន៍ដល់កាសែតមតិជនថា ការដែលព្រះពុទ្ធជាបកាសិត ឬព្រះធម៌កើតពីអាទិទេពនោះជាការអាងតាមប្រវត្តិសាស្ត្ររបស់គ្រីស្តថាពេលវត្ថុគ្រប់យ៉ាងអាទិទេពសាងឡើងក៏ជាការសរុបថាព្រះពុទ្ធជាម្ចាស់ឬព្រះធម៌កើតពីអាទិទេព។ តើរ៉ូម៉ាំងកាតូលិកទទួលស្គាល់ហេតុផលខាងប្រវត្តិសាស្ត្រមែនឬ?

វរសេនីឯកគឹង កិសួរ តាំងសេចក្តីសង្កេតថា

១. ពួកយិវបដិសេធន៍ព្រះយេស៊ូថាមិនមែនជាអាទិទេព រហូតដល់មានការចង់ច្ងាង តែគ្រីស្តបែរជាប្រឆាំងនឹងប្រវត្តិសាស្ត្រថាយេស៊ូជាព្រះអាទិទេព ។

២. ហើយថាព្រះយេស៊ូកើតពីព្រះម៉ែម៉ារីបរិសុទ្ធិ តែហេតុអ្វីបានជាព្រះយេស៊ូមានទំនាក់ទំនងជាមួយស្តេចដេវីដ ដែលជាបុព្វបុរសរបស់យោសេស? ព្រោះព្រះយេស៊ូមិនបានកើតពីយោសេសទេឬ? ចង់ច្នាក់ប្រវត្តិសាស្ត្រយ៉ាងណា ទើបឲ្យព្រះយេស៊ូជាបុត្ររបស់ដេវីដបាន?។

៣. គ្រីស្តអះអាងថា យេស៊ូជាអាទិទេពដោយបដិសេធន៍ពួកយិវ តែហេតុអ្វីក៏ពួកគ្រីស្តបដិសេធន៍មោហាម៉ាត់ថាមិនមែនជាអាទិទេព។ ហើយការចង់ច្នាក់ប្រវត្តិសាស្ត្រដូចនេះ

ទើបមានប្រយោគនៅក្នុងសាសនាគ្រីស្ទថា អ្នកកាន់សាសនាដទៃ ចូរពិចារណាទ្រឹស្តីសាសនារបស់អ្នក ហើយពិចារណាឃើញអ្វីដែលមិនសមរម្យត្រឹមត្រូវ ចូរលះបង់សាសនារបស់អ្នក ហើយផ្លាស់មកកាន់សាសនារបស់យើង ។

តែបែរជាបង្រៀនពួកអ្នកកាន់សាសនាខ្លួនថា អ្នកចូរកុំសង្ស័យឬរើកញែកខុសត្រូវពាក្យពេជ្រក្នុងសាសនារបស់យើង ព្រោះជាការប្រចាំងនឹងសច្ចភាពរបស់អាទិទេព។ ឬបើពិចារណាក៏ត្រូវមានជំនឿឲ្យមោះមុត បើមិនដូច្នោះអ្នកអាចនឹងត្រូវដាក់ទោសទណ្ឌកម្មធ្លាក់ទៅក្នុងនរកជាក់ជាមិនខាន។

ព្រះពុទ្ធជាម្ចាស់មិនមែនបកាសិតរបស់អាទិទេពឬព្រះយេហូវ៉ាទេ ព្រោះព្រះអង្គបដិសេធន៏តាំងពីដំបូងនូវការមិនមានពិតនូវតួអង្គអាទិទេព ហើយព្រះអង្គថានោះជាតួអវិជ្ជាដែលធ្វើឲ្យព្រះអង្គត្រូវប្រើពេលជាច្រើនឆ្នាំ មិនបានត្រាស់ជាព្រះពុទ្ធ។ បើមានព្រះអាទិទេពពិតប្រាកដគឺ**សហម្បតីព្រហ្ម** ដែលជាព្រះព្រហ្មមកលុតជង្គង់អារាធនាអង្វរសូមឲ្យព្រះពុទ្ធជាម្ចាស់ សំដែងធម៌ដើម្បីប្រោសសត្វលោកទាំងឡាយ ។

### *តើព្រះពុទ្ធអង្គត្រាស់ដឹងព្រះធម៌បានយ៉ាងណា នៅពេលដែលគ្មានអាទិទេពជួយ?*

ចំណុចនេះលោកសាស្ត្រាចារ្យរិស ដេវិដ ធ្លាប់បានសរសេរថាពាក្យថា **ហ្គត់(God)** វិវឌ្ឍន៏មកពីពាក្យ **គោតមៈ**នោះឯង តែយើងនឹងមិនយករឿងនេះមកអាធិប្បាយយកឈ្នះយកចាញ់អ្វីឡើយ។ ព្រះអង្គត្រាស់ដឹងដោយការប្រឹងប្រែងព្យាយាម ប្រកបដោយសម្មាទិដ្ឋិនិងសម្មាសង្កប្បៈ ដែលព្រះអង្គទ្រង់សរសើរនូវសក្តានុពលរបស់មនុស្ស មានកំឡាំងខ្លាំងលើសលប់ជាងពួកទេវៈទាំងឡាយ ដែលពួកនោះគ្រាន់តែសោយនូវផលបុណ្យកុសលកម្មរបស់ខ្លួនតែប៉ុណ្ណោះ តែមិនអាចសំរេចព្រះនិព្វានបានឡើយ ។

ព្រះពុទ្ធអង្គហាមឲ្យគេពិសោធន៍ព្រះអង្គនូវរឿងសំខាន់ ៤ គឺ :

១. ជាព្រះអរហាត្តសម្មាសម្ពុទ្ធ ដូចជាត្រាស់ដឹងអរិយសច្ច បដិច្ចសមុប្បាទធម៌អនត្តា ជាដើម ។

២. ជាព្រះខីណាសព លះកាម លះភព ទិដ្ឋិ និងអវិជ្ជាបានទាំងស្រុង ។

៣. អ្វីដែលខ្លួនធ្វើគឺឲ្យផលតាមកម្មនោះ ធ្វើល្អបានល្អ ធ្វើអាក្រក់បានអាក្រក់

៤. ធម៌ណាដែលសំដែងថាមានប្រយោជន៍ដល់អ្នកធ្វើ ធម៌នោះនឹងមានដូច្នោះជារៀងរហូត មិនមានការកែប្រែជាប្រការដទៃឡើយ ។

ជារឿយៗ យើងច្រើនគិតថាធម្មជាតិគ្រប់យ៉ាងសុទ្ធតែមានអ្នកសាង តែមិនដែលគិតថា តើនរណាសាង?។ តាមពិត គឺមានតែយើងទេជាអ្នកកសាងដោយខ្លួនឯង ។

## អាទិទេពនិងព្រះពុទ្ធ តើនរណាគេរាប់អានជាងក្នុងខ្សែរចក្ខុរបស់វិញ្ញូជន?

## កាសែត២ ភាគ២

រឿងនេះមិនគួរយកមកនិយាយ តែបើគេថាព្រះពុទ្ធគ្រាន់តែជាអ្នកនាំសារព្រះអាទិទេព្យ យើងគួរលើកមកនិយាយខ្លះ។ អាទិទេពខ្លះចូលចិត្តឲ្យគេគោរពបូជា ទើបអ្នកនោះទទួលការប្រោសប្រណីតែបើមិនគោរពបូជាទេច្បាស់ជាព្រះអាទិទេពនោះនឹងដាក់បណ្តាសារ។អាទិទេពអង្គខ្លះចូលចិត្តឲ្យគេសែនសំណូកសូកប៉ាន់ មានការសំឡាប់សត្វបូជាយញ្ញជាដើម ដែលការបូជានោះនាំសេចក្តីមានបានមកឲ្យអ្នកបួសគេតែប៉ុណ្ណោះ។ យើងនឹងមិនលើកយកចំណុចនេះមកអធិប្បាយឲ្យលំអិតទាំងអស់ទេ ។

ព្រះពុទ្ធអង្គទ្រង់សំដែងថា មនុស្សយើងល្អឬអាក្រក់ គឺអាស្រ័យនឹងកម្មរបស់ខ្លួន ព្រះពុទ្ធអង្គក៏បរិនិព្វានទៅហើយ តែទ្រឹស្តីកម្មផលនេះនៅតែទាន់សម័យជានិច្ច។ ចំណែកអាទិទេពសាសនាគ្រឹស្តដែលគេតែងតែប្រាប់យើងថា នៅរស់សព្វថ្ងៃនេះ តើអាទិទេពអង្គនោះទៅណាបានជាបណ្តោយឲ្យផលិតផលដែលខ្លួនបានបង្កើតឡើង ឈ្លោះទាស់ទែងគ្នា សំឡាប់កាប់ចាក់

គ្នា គ្រោះធម្មជាតិ និងមេរោគផ្សេងៗបៀតបៀនឥតឈប់ឈរ?។ ការប្រៀបធៀបគឺអាស្រ័យការសំដែងចេញខាងផ្លូវកាយ វាចា និង ចិត្ត ដោយជ្រើសយកទីអាងក្នុងគម្ពីរព្រះត្រៃបិដក និងគម្ពីរប៊ីប។

១. ផ្នែកបញ្ញា តើនរណាមានបញ្ញាច្រើនជាងនរណា?

១.១. កាតូលិកប្រាប់ថាអាទិទេពមានព្រះទ័យស្រឡាញ់អាណិតអាសូរដល់សត្វលោកមានការបង្កើតមនុស្ស សត្វ និងទេវតាឲ្យសុខសប្បាយជាមួយ តែទេវតាឈ្មោះ **លូស៊ីហ្វើរ**ក្បត់ព្រះអាទិទេព ទើបត្រូវដាក់ទោសធ្លាក់ចូលទៅក្នុងនរកក្លាយជាបិសាច។ នេះបញ្ជាក់ថាអាទិទេពបានសាងទេវតាបក្សពួករបស់ខ្លួន តែមិនមានបញ្ញាដឹងថាទេវតាលូស៊ីហ្វើរក្បត់ខ្លួន។ ព្រះពុទ្ធអង្គមិនបានបង្កើតនរណា គេកើតក៏ព្រោះតែកម្មរបស់ខ្លួនគេ ហើយព្រះអង្គទ្រង់បង្រៀនហេតុផលដែលព្រះអង្គបានត្រាស់ដឹងល្អហើយ ព្រះអង្គទេសនាកន្លែងណា ព្រះអង្គទ្រង់ជា**ពុទ្ធវេនេយ្យៈ**ដែលដឹងចិត្តមនុស្សជានិច្ច ។

១.២. ព្រះអាទិទេពពោលក្នុងគម្ពីរសញ្ញាចាស់ថា បើមានហេតុអាក្រក់កើតឡើងចំពោះជីវិត ប៉ះជើងសងជើង ប៉ះដៃសងដៃ ប៉ះភ្នែកសងភ្នែក បើវាយធាក់សងវិញដោយវាយធាក់ តែព្រះពុទ្ធអង្គសំដែងក្នុងគម្ពីរព្រះធម្មបទថា ចូរឈ្នះកំហឹងដោយការមិនខឹង ចូរឈ្នះអំពើអាក្រក់ដោយអំពើល្អ គួរឈ្នះមនុស្សកំណាញ់ដោយការឲ្យទាន គួរឈ្នះមនុស្សនិយាយស្តីកុហក់បោកប្រាស់មិនបានការ ដោយការនិយាយពាក្យពិតពីរោះមានប្រយោជន៍ ។

១.៣. ព្រះអាទិទេពបង្រៀនមនុស្សដើម្បីឲ្យទៅកើតនៅឋានសួគ៌ាស្ថិតនៅក្បែរ តែព្រះពុទ្ធអង្គបង្រៀនឲ្យមនុស្សទាំងអស់ទទួលបាននូវសេចក្តីសុខទាំងលោកបច្ចុប្បន្ននេះ ទាំងនៅឋានសួគ៌ា និងព្រះនិព្វាន ដែលព្រះនិព្វាននេះព្រះអាទិទេពទៅមិនដល់ទេ ។

១.៤.  ព្រះអាទិទេពមិនបានបង្រៀនធម៌អរិយសច្ច៤និងទ្រឹស្តីបដិច្ចសមុប្បាទទាំងនៅក្នុងគម្ពីរសញ្ញាចាស់និងសញ្ញាថ្មី តែព្រះពុទ្ធអង្គបានត្រាស់ដឹងធម៌អរិយសច្ច៤ ហើយបង្រៀនធម៌ច្រើនយ៉ាងដែលអាចសរុបបញ្ចូលទៅក្នុងអរិយសច្ច៤បានទាំងអស់ ។

២.  ព្រះអាទិទេពក្នុងឋានៈជាអ្នកបង្កើតលោក ជាមួយព្រះពុទ្ធអង្គក្នុងឋានៈជាអ្នកបំពេញសេចក្តីល្អក្នុងភាពជាមនុស្ស រហូតដល់ត្រាស់ដឹងជាព្រះពុទ្ធឆ្ងាយចាកសឹកសត្រូវពោលគឺកិលេស ដូច្នេះតើនរណាមានករុណាធម៌ដល់សត្វលោកច្រើនជាង?

២.១.  ក្នុងគម្ពីរសញ្ញាចាស់ពោលទុកថាព្រះយេហូវ៉ាបានប្រទានច្បាប់ក្នុងការធ្វើសង្គ្រាមថា ពេលអ្នកលើកទ័ពចូលទៅវាយកំចាត់សត្រូវ ចូរអ្នកកុំអាលចូលទៅភ្លាមៗ ត្រូវនិយាយបញ្ចុះបញ្ចូលឲ្យគេចុះចាញ់សិន បើគេព្រមចុះចាញ់ ចូរអ្នកកុំធ្វើឲ្យគេមានអន្តរាយ តែអ្នកត្រូវនាំយកពួកគេមកធ្វើជាឈ្លើយសឹកជាខ្ញុំបំរើ តែបើគេមិនព្រមចូរលើកទ័ព វាយកំចាត់ប្រទេសនោះឲ្យរលាយសាបសូន្យទៅ ហើយយើងជាព្រះបិតានៃអាទិទេព នឹងជួយអ្នកឲ្យវាយកំចាត់សត្រូវទាំងនោះឲ្យស្លាប់វិនាសសាបសូន្យ ហើយអ្នកចូរសំឡាប់ប្រជាជនទាំងអស់នោះ មានបុរសៗដោយដាវដែលមុតស្រួចរបស់អ្នក ចំណែកប្រជាជនដែលជាស្ត្រីនិងក្មេងៗទារកនិងសត្វផ្សេងៗ ឬទ្រព្យសម្បត្តិដែលមានក្នុងប្រទេសដែលយើងដណ្តើមបាន ចូរអ្នកប្រមូលយកមកធ្វើជារបស់អ្នកទៅព្រោះអាទិទេពបានប្រទានឲ្យអ្នកហើយ។ ចំណែកព្រះពុទ្ធអង្គមិនដែលធ្លាប់បង្រៀនដូចនេះ គ្រាមួយនោះញាតិរបស់ព្រះពុទ្ធអង្គ ត្រកូល**សក្យ**ៈនិង**កូលិយ**ៈកំពុងត្រៀមធ្វើសង្គ្រាមដើម្បីដណ្តើមយកទឹកនៅក្នុងទន្លេ**រោហិណី** ព្រះពុទ្ធអង្គស្តេចទ្រង់យាងទៅកាន់ទីនោះហើយពេលជ្រាបដឹងរឿងនោះហើយទ្រង់សួរថា តើទឹកនិងត្រកូលក្សត្រិយ៍មួយណាសំខាន់ជាង មហាបពិតឆ្លើយថា ត្រកូលក្សត្រិយ៍មានតំលៃខ្លាំងជាងទឹកក្នុងទន្លេ បើដូច្នោះតើការសំឡាប់រង្គាលគ្នាដើម្បីដណ្តើមយកទឹកទន្លេនេះជាការគួរសមឬ? បន្ទាប់មកក៏បានត្រាស់ជាគាថាទុកសំរាប់ដាស់តឿនថា ក្នុងចំណោមមនុស្សដែលមានពៀរវេរានឹងគ្នា

យើងអ្នកគ្មានពៀរវេរានឹងនៅជាសុខ ដូច្នេះក្នុងចំណោមមនុស្សដែលមានពៀរវេរានឹងគ្នា ចូរយើងជាអ្នកគ្មានពៀរវេរាចុះ ក្នុងចំណោមអ្នកដែលទុក្ខក្តៅក្រហាយយើងគ្មានសេចក្តីទុក្ខក្តៅក្រហាយ ចូរអ្នកជាមនុស្សដែលគ្មានសេចក្តីក្តៅក្រហាយចុះ ក្នុងចំណោមមនុស្សដែលរឹករវ យើងជាមនុស្សដែលគ្មានភាពរឹករវឡើយ ចូរយើងជាមនុស្សដែលគ្មានសេចក្តីរឹករវចុះ។ នៅពេលព្រះពុទ្ធអង្គទ្រង់ត្រាស់នូវគាថានាំឱ្យគិតដូចនេះ ព្រះញាតិទាំងពីរភាគីក៏ឈប់ធ្វើសង្គ្រាម ហើយមកស្រុះស្រួលរួមរស់ជាមួយគ្នា។ ក្រៅពីនោះ ព្រះពុទ្ធអង្គទ្រង់ប្រារព្ធដល់ព្រះបាទ**បសេនទិកោសល**ដែលចាញ់សង្គ្រាមដល់ទៅបីដងថា អ្នកឈ្នះនឹងបង្កើតនូវពៀរវេរា អ្នកចាញ់នឹងដេកជាទុក្ខបុគ្គលដែលអាចលះបានទាំងការឈ្នះនិងការចាញ់ នឹងរស់នៅយ៉ាងស្ងប់សុខ។

២.២. ព្រះអាទិទេពបានពោលក្នុងបទបញ្ញត្តិថា បើមានសំបុកសត្វនៅពីមុខលើដើមឈើឬលើដី មានពងនិងកូនខ្ចីដែលមេវាកំពុងក្រាប អ្នកចូរយកពងសត្វនោះទៅ តែត្រូវពន្លែងឱ្យមេវារួចខ្លួនចុះ ចំណែកកូនសត្វអ្នកយកមកចិញ្ចឹមទុកក៏បានដើម្បីការចំរើន នេះគឺការបង្រៀនរបស់អាទិទេព។ ព្រះពុទ្ធអង្គទ្រង់មិនបង្រៀនបែបនេះទេ ព្រះអង្គទ្រង់ឧទានឡើងពេលត្រាស់ដឹងថ្មីៗថា ការមិនបៀតបៀនគ្នាគឺការសង្រួមរវាំងចំពោះជីវិតសត្វទាំងឡាយ ជាសេចក្តីសុខក្នុងលោក។

២.៣. ក្នុងព្រះគំរាស់បញ្ញត្តិចាស់ អ្នកទាំងឡាយចូរកុំមេត្តាប្រាណីគេ តែយកជីវិតជំនួសជីវិត ភ្នែកជំនួសភ្នែក ធ្មេញជំនួសធ្មេញ ដៃជំនួសដៃ ជើងជំនួសជើង ជាការបង្រៀនឱ្យមានការព្យាបាទគ្នាយ៉ាងច្បាស់ក្រឡែតដែលខុសពីព្រះពុទ្ធអង្គ។ ព្រះពុទ្ធជួបក្មេងដែលកំពុងដេញវាយពស់ទ្រង់ត្រាស់សួរ ពេលដែលដឹងរឿងហើយ ទ្រង់ត្រាស់ទៅក្មេងទាំងនោះថា សត្វទាំងឡាយរមែងខ្លាចការវាយធ្វើបាបធ្វើឱ្យចុកចាប់ មនុស្សគួរធ្វើខ្លួនឯងជាតួឧបមាហើយ មិនគួរសំឡាប់ មិនគួរបៀតបៀន ឬប្រើឱ្យអ្នកដទៃសំឡាប់ ឱ្យអ្នកដទៃបៀតបៀនឡើយ។

៣.	បញ្ញត្តិ១០ប្រការ ខដំបូងរបស់ព្រះអាទិទេពគឺចូរកុំសំឡាប់មនុស្សតែសីលប្រាំខ ដំបូងរបស់ព្រះពុទ្ធអង្គគឺហាមប្រាមមិនឲ្យមានការសំឡាប់វត្ថុមានជីវិតទាំងឡាយ ។

ទាំងនេះជាការប្រៀបធៀបពីអាទិទេពដែលបង្កើតលោកទាំងឡាយ និង ព្រះពុទ្ធអង្គ ដែលជាអ្នកត្រាស់ដឹងរួមរស់ជាមួយមនុស្សលោកទាំងឡាយ ព្រះអង្គជាអ្នកដែលដុត បំផ្លាញនូវអវិជ្ជាបានមុន ទើបព្រះអង្គមានសេចក្តីមេត្តាករុណាដល់កូនៗ របស់ព្រះ អង្គយ៉ាងណា ចូរកុំភ្លេចថាអាទិទេពស្វាមីភក្តិចំពោះតែមនុស្សក្រុមជាមួយគ្នា តែ ប៉ុណ្ណោះ តែព្រះពុទ្ធអង្គមានស្វាមីភក្តីចំពោះសត្វមានជីវិតគ្រប់ប្រភេទ មិនថាជា មនុស្សឬសត្វ។ មេត្តាករុណារបស់ព្រះពុទ្ធអង្គគឺស្មើទាំងមនុស្សនិងសត្វ ដូចដែល ទេវទត្តមានគំនុំគំគួនតាមព្យាបាទព្រះពុទ្ធអង្គមកយូរយារនោះ តែមុននឹងចូលបរិនិព្វាន ព្រះអង្គបានប្រាប់ឲ្យសិស្សរបស់ព្រះអង្គជ្រាបថា ព្រះពុទ្ធអង្គមានមេត្តាករុណាស្មើគ្នាជា និច្ចចំពោះ**ដំរីនាឡាគិរី ចោរអង្គុលីមារ ព្រះទេវទត្ត និងព្រះរាហុល**។ ព្រោះហេតុដូច នោះ ធម៌សូត្រធ្វើវត្តព្រឹកល្ងាចរំលឹកដល់ព្រះពុទ្ធអង្គថាព្រះអង្គមានមេត្តាករុណា ចំពោះសព្វសត្វជានិច្ច, ព្រះអង្គមានបញ្ញាដែលកើតពីការត្រាស់ដឹងពិតប្រាកដ និង មានព្រះទ័យដែលបរិសុទ្ធិពិតប្រាកដ ព្រះទ័យដែលប្រាសចាកលោភៈ ទោសៈ និង មោហៈ ។

៣.១. គោលសំខាន់របស់សាសនាគ្រឹស្ត អះអាងយ៉ាងខ្លាំងថាអាទិទេពជាអ្នកបរិសុទ្ធិ ជ្រះស្អាតជាងអ្វីទាំងអស់ យើងជាអ្នកជំពាក់គុណសេចក្តីស្រឡាញ់និងមេត្តារបស់ព្រះ អាទិទេព ត្រូវតែគោរពសក្ការៈនិងក្រាបបង្គំព្រះអង្គ ព្រះអាទិទេពទ្រង់ព្រះជន្មាយុជា រៀងរហូត បានទ្រង់បង្ហាញខ្លួនដល់យើងក្នុងឋានៈជាព្រះបិតា ព្រះបុត្រ និងព្រះ វិញ្ញាណបរិសុទ្ធិ ដែលបង្ហាញបញ្ជាក់នូវភាពបរិសុទ្ធិ។ ចំណុចនេះ គឺពិបាកនឹងប្រៀប ធៀប ព្រោះអ្នកបរិសុទ្ធិក្នុងព្រះពុទ្ធសាសនាមានន័យថា ប្រាសចាកកិលេសទាំងពួង

បានដល់ព្រអរហន្តទាំងបីប្រភេទគឺព្រះសម្មាសម្ពុទ្ធអង្គ ព្រះបច្ចេកពុទ្ធ និងព្រះអរហន្តសាវ័ក។ បើយកចំណុចនេះទៅប្រៀបធៀបនឹងព្រះអាទិទេពនឹងមានបញ្ហាចោទឡើង។ រឿងនេះ អតីតព្រះមហាក្សត្រថៃបានសង្ស័យចំពោះមេត្តា ករុណា ការអាណិតអាសូរ ភាពយុត្តិធម៌ បរិសុទ្ធិរបស់ព្រះយេហូវ៉ា នៅក្នុងការសន្ទនាគ្នាក្នុងកថាខណ្ឌទី៤ ម៉ូសេសនៅពេលដែលដើរគេចពីយ៉ាគុបមកទន្លេក្រហមគេបានបួងសួងឲ្យព្រះអាទិទេពធ្វើឲ្យទន្លេក្រហមញែកចេញជាពីរ ហើយទន្លេក៏ស្ងួតអាចធ្វើឲ្យពួកគេដើរឆ្លងផុតបាន យ៉ាគុបដែលដេញតាមពីក្រោយមកដល់ ព្រះអាទិទេពបានធ្វើឲ្យទឹកហូរចូលពេញដូចដើម ធ្វើឲ្យពលទាហានរបស់យ៉ាគុបពីក្រុងហ្សារ៉ូលង់ទឹកស្លាប់អស់ទៅ ព្រោះតែអំណាចរបស់អាទិទេព។ ចំណុចបញ្ជាក់ថាក្រុមម៉ូសេសត្រូវបានអាណិតអាសូរដោយអាទិទេព តែក្រុមដែលប្រឆាំងម៉ូសេសត្រូវបានកំទេច សួរថាតើព្រះអាទិទេពមានយុត្តិនៅកន្លែងណា? ព្រោះថាពួកក្រុមយ៉ាគុបក៏ត្រូវបានបង្កើតដោយអាទិទេពដែរ ដូច្នេះជនជាតិយ៉ាគុបក៏ជាបុត្ររបស់ព្រះអាទិទេពដូចគ្នា ហើយម៉ូសេសនិងយិវក៏ជាបុត្រអាទិទេពដូចគ្នា ចុះហេតុអ្វីបានជាអាទិទេពមានការស្រឡាញ់និងការស្អប់ចំពោះបុត្ររបស់ខ្លួន?

តែសំរាប់ព្រះពុទ្ធអង្គ យើងអាចលើកយកព្រះតំរាស់របស់ព្រះអង្គដែលថាព្រះអង្គទ្រង់បរិនិព្វានទៅហើយ មានតែព្រះធម៌ដែលព្រះអង្គបានត្រាស់ដឹងជាសាសតារបស់អ្នកទាំងឡាយ។ ព្រះអង្គមិនបានថា ព្រះអង្គជាអ្នកកសាងធម៌ទេ ប៉ុន្តែបើព្រះអង្គថាព្រះអង្គជាអ្នកបង្កើតធម៌ ក៏គង់នឹងមានមនុស្សជាច្រើនជឿព្រះអង្គ។ ដោយសារតែកិលេសដែលជាគ្រឿងសៅហ្មងត្រូវបានកំចាត់អស់ពីខន្ធសន្តានហើយ ព្រះអង្គនឹងមិននិយាយអ្វីដែលជាពាក្យបំផ្លើសឬពាក្យមិនពិតឡើយ។ សេចក្តីពិតយ៉ាងណា ព្រះអង្គទ្រង់សំដែងយ៉ាងនោះ។ ព្រះអង្គជាអ្នកចង្អុលផ្លូវប្រាប់យើងតែប៉ុណ្ណោះ ចំណែកការបដិបត្តិដើម្បីឲ្យបានផល្លានិសង្សផ្សេង។ បុគ្គលម្នាក់ៗត្រូវតែជាអ្នកធ្វើដោយខ្លួនឯង ទោះបីជាមនុស្សចាប់តោងស្បៃចីវរទៅជាមួយព្រះ

អង្គ តែមិនបដិបត្តិធម៌សមគួរដល់ធម៌ ក៏មិនអាចគេចផុតពីទង្វើកម្មខ្លួនឯងបានឡើយ ដូចគ្នានឹងពែកដែលដួសសម្លមិនអាចធ្វើឲ្យរស់ជាតិរបស់សម្លផ្លាស់ប្តូរបានឡើយ។ ពេលដែលព្រះអង្គទ្រង់ព្រះអាពាធ ព្រះអង្គមិនទ្រង់អនុញ្ញាតឲ្យព្រះភិក្ខុព្យាបាលជំងឺ បើចង់ព្យាបាលសូមឲ្យព្យាបាលភិក្ខុអង្គផ្សេងដែលមានជំងឺ។

៣.២.ព្រះពុទ្ធអង្គបានសំដែងការបូជាពីរយ៉ាង តែទ្រង់សរសើរការបដិបត្តិបូជា ដែលអ្នកបដិបត្តិនឹងទទួលបានផលដោយខ្លួនឯង។ ចំណែកព្រះអាទិទេព ដែលជានិច្ចជាកាលឲ្យសាវ័កទាំងឡាយស្វាមីភក្តិចំពោះព្រះអង្គឯងម្នាក់គត់ ធ្វើដូច្នេះពេលស្លាប់ទៅនឹងទៅកើតបំរើព្រះអាទិទេពនៅឋានសួគ៌ថែមទៀត។ ពេលសង្កេតឃើញដូច្នេះហើយ សមនឹងពាក្យរបស់លោកសាស្ត្រាចារ្យរីស ដេវីស និយាយថា **ហ្គត់** មកពីពាក្យថា **គោត្តម**។ នេះសបញ្ជាក់ឲ្យឃើញថានរណាជាអ្នកបង្កើតនរណា ប៉ុន្តែពុទ្ធបរិស័ទនឹងមិនមានការប្រៀបធៀបខាងណាប្រសើរជាងខាងណា ដូចដែលសាស្ត្រាចារ្យ**ម៉ូស៊ីអុក ម៉ូស្តានិន** ពោលនៅក្នុងសាសនាប្រៀបធៀបរបស់លោកថា ព្រះពុទ្ធមិនមែនជាព្រះអាទិទេពទេ ហើយព្រះអាទិទេពក៏មិនមែនជាព្រះពុទ្ធដែរ បុគ្គលទាំងពីរនេះមានភាពខុសគ្នាឆ្ងាយណាស់ទាំងបញ្ញា មេត្តាករុណា និងសេចក្តីពិតដែលឈរលើហេតុផល ។

ដើម្បីឲ្យសាសនាទាំងពីរ គឺព្រះពុទ្ធសាសនានិងសាសនាគ្រឹស្តរស់នៅរួមរស់ជាមួយគ្នាបាន គួរតែមានអធិប្បាយឲ្យត្រឹមត្រូវតាមសភាវពិតដែលមានក្នុងគម្ពីររបស់ខ្លួនមិនត្រូវប្រើយុទ្ធសាស្ត្របំផ្លាញគ្នាដោយការបួលបង្កាច់គ្នាឡើយ ។

### *សាសនាគ្រប់សាសនាបង្រៀនឲ្យមនុស្សល្អមែនទេ?*

ពាក្យនេះ ត្រូវបាននិយាយនិងយកមកប្រើយ៉ាងទូលំទូលាយ ដើម្បីឲ្យមានការព្រមព្រៀងគ្នា ឬក៏ដើម្បីធ្វើគំរោងការលេបយកសាសនាផ្សេងទៀតក៏ថាបាន។ តែតាមពិត ការសំរេចចិត្តថាល្អឬអាក្រក់ ច្រើនយកការគិតឃើញរបស់ខ្លួនជាធំដែល

បានទទួលឥទ្ធិពលសាសនាដែលខុសគ្នា ឬទិន្នានយោបាយដែលខុសគ្នា។ រឿងសាសនាច្រើនមានភាពខុសគ្នា ទាំងផ្នែកសីលធម៌ ការបដិបត្តិ អាចមានគោលដៅឲ្យមនុស្សរស់នៅរួមគ្នាជាសុខ តែចំពោះជំនឿ ច្រើនកើតចេញពីទិដ្ឋិ ដូចជាមិច្ឆាទិដ្ឋិរបស់ព្រះពុទ្ធសាសនា អាចជាសម្មាទិដ្ឋិរបស់សាសនាគ្រីស្តផងដែរ ដូចជាការជឿថាមានអាទិទេពបង្កើតពិភពលោកជាការយល់ខុសខ្លាំងណាស់ក្នុងព្រះពុទ្ធសាសនា។ សាសនាគ្រីស្តសង្កត់ធ្ងន់ទៅលើសទ្ធា តែព្រះពុទ្ធសាសនាសង្កត់ធ្ងន់ទៅលើបញ្ញា។ គោលដៅខ្ពស់បំផុតរបស់សាសនាគ្រីស្ត គឺការបានទៅរួមរស់ជាព្រះអាទិទេពជានិច្ចនិរន្តរ៍ តែទិសដៅខ្ពស់បំផុតរបស់ព្រះពុទ្ធសាសនាគឺស្ថិតលើការរំដោះខ្លួនចេញផុតពីខ្ញុំ បំរើ និង ការជាប់ជំពាក់គ្រប់រូបបែប នោះគឺព្រះនិព្វាន។ ព្រះពុទ្ធសាសនាសរសើរការសំឡាប់ទោសៈ តែគ្រីស្តសាសនាសរសើរការសំឡាប់ចោរសត្រូវដែលក្បត់មតិព្រះអាទិទេព ឬ ជីវិតដែលយកមកធ្វើបូជាយញ្ញដល់ព្រះអាទិទេពជាដើម។ គ្រីស្តសាសនិកជនអាចនឹងជ្រាបថាពាក្យប្រៀនប្រដៅរបស់ព្រះយេហូវ៉ាទាំង**៦១៣វគ្គ** ដែល**យស្សាយ៉ា**សង្ខេបសល់តែ **៣វគ្គ** ដូចជា ១.ចូរមានយុត្តិធម៌ ២.មានសេចក្តីស្រឡាញ់អាណិត និង ៣.ចូរធ្វើដំណើរតាមព្រះអាទិទេពយ៉ាងគោរពហ្មត់ចត់។ តាមធម៌ទាំងបីយ៉ាងនេះជាការសមរម្យទេ ដែលយកព្រះពុទ្ធអង្គទៅប្រកាសត្រឹមតែជាអ្នកនាំសាររបស់អាទិទេព? ដែលព្រះពុទ្ធអង្គគឺជាអ្នកត្រាស់ដឹងធម៌ដល់ទៅ**៨៤០០ព្រះធម្មខណ្ឌ**។

## ព្រះយេស៊ូជាព្រះសិរីអារិយមេត្រីពិតឬ?

ការអះអាងថាព្រះយេស៊ូជាព្រះសិរីអារិយ៍នោះជាការប្រើនយោបាយចិត្តវិទ្យាដែលមានពុទ្ធិសាសនិកជនមួយចំនួនដែលរំពឹងសង្ឃឹមចំពោះតែព្រះសេអារិយ៍ ដើម្បីទាញមកឲ្យគោរពរាប់អានសាសនាគ្រីស្ត។ គ្រូគង្វាលម៉ានុប ជួបសម័យ សរសេរថាបើព្រះពុទ្ធអង្គទ្រង់ព្យាករណ៍ថា នឹងមានព្រះសិរីអារ្យមេត្រីមកបដិសន្ធិបន្ទាប់ព្រះអង្គហើយនឹងក្លាយជាព្រះពុទ្ធ

នោះ ខណៈនេះគឺកំពុងគង់ប្រថាប់នៅឋានតុសិតដើម្បីការពារព្រះពុទ្ធសាសនា។ តែចុង បញ្ចប់នៃអត្ថបទនិយាយថា ព្រះសិរីអារ្យមេត្រីដែលមកចាប់បដិសន្ធិនោះគឺព្រះយេស៊ូ។ បើដូច្នោះមែន ហេតុអ្វីបានជាសាសនិកព្រះយេស៊ូ ស្រេកឃ្លានក្នុងការទាក់ទាញយកសាសនិករបស់ខ្លួន មានគំរោងបំផ្លាញព្រះពុទ្ធសាសនាព្រមទាំងមានមហិច្ឆតាចង់ធ្វើឲ្យពិភពលោកទាំងមូលក្លាយជាគ្រីស្តសាសនិកទាំងអស់?។ ពិសេសសំខាន់ជាងនេះនោះ ប្រព័ន្ធក្នុងព្រះពុទ្ធសាសនា មិនមែនកើតឡើងពីប្រព័ន្ធតែងតាំងដូចជាឪពុកតែងតាំងកូន ឬសាច់ញាតិរបស់ខ្លួននោះទេ ការក្លាយទៅជាព្រះពុទ្ធមួយព្រះអង្គៗគឺកើតពីតេជៈបារមីសន្សំរាប់អសង្ខ័យជាតិ។ ឬការនិយាយថាអាទិទេពតែងតាំងព្រះសិរអារិយមេត្រី ហើយព្រះសិរអារិយមេត្រីគឺព្រះយេស៊ូនោះ មានន័យថា ព្រះយេស៊ូគឺគ្រាន់តែជាអ្នកប្រកាសរបស់ព្រះពុទ្ធអង្គតែប៉ុណ្ណោះ។ យ៉ាងណាក៏ដោយព្រះពុទ្ធអង្គត្រាស់ថា ព្រះសិរីអារ្យមេត្រីនឹងមកកើតមានលក្ខណៈដូចតទៅ :

១. ពិភពលោកយើងរលំរលាយរហូតដល់អាយុមនុស្សនៅត្រឹម១០ឆ្នាំ ក្រោយពីនោះទើបមានការភ្ញាក់រលឹកដោយខ្លួនឯង ហើយអាយុក៏កើនឡើងរហូតដល់មានព្រះសិរីអារ្យមេត្រីមកបដិសន្ធិ ។

៣. ព្រះពុទ្ធគ្រប់ព្រះអង្គរួមទាំងព្រះសិរីអារ្យមេត្រីត្រូវមានសប្បុរិសលក្ខណៈ៣២ប្រការ បរិបូរដោយអនុព្យញ្ជនៈ៨០ប្រការ ។

៤. ធម្មតាព្រះពុទ្ធអង្គទាំងឡាយជាព្រះអរហំ ត្រាស់ដឹងដោយល្អ ដោយប្រពៃចំពោះព្រះអង្គឯង បរិបូរដោយព្រះពុទ្ធគុណទាំងឡាយ ៩ ។

៥. ការបរិនិព្វានរបស់ព្រះពុទ្ធអង្គ គឺប្រព្រឹត្តទៅយ៉ាងស្ងប់ស្ងៀមក្នុងឈានកម្មដ្ឋាន មិនមានការភ័យតក់ស្លុត កោះហៅអ្នកដទៃមកជួយខ្លួនឡើយ ។

៦. នៅក្នុងរឿងព្រះមាលៃមានអធិប្បាយថា នៅសម័យព្រះសិរីអារ្យមេត្រី ទឹកនៅក្នុងស្ទឹងហូរចុះម្ខាងបញ្ច្រាសទិសគ្នា មនុស្សពោរពេញទៅដោយសេចក្តីសុខ មានសំរស់ស្អាតដូចគ្នា មានដើមកាលព្រឹក្សដុះជុំវិញក្រុង មនុស្សចង់បានអ្វី គ្រាន់តែទៅអធិដ្ឋាននៅដើម

នោះ នឹងបានតាមសេចក្តីប្រាថ្នាដាដើម ។

នៅក្នុងសៀវភៅ ចំណង់ជើងថា យើងគឺបុគ្គលដែលមនុស្សលោករង់ចាំ សរសេរដោយលោក សាម៉ន រឿងចាន ព្រះយេស៊ូគឺព្រះសិរីអារ្យមេត្រី ដែលជនជាតិថៃកំពុងរង់ចាំ។ ដើម្បីទាក់ទាញពុទ្ធសាសនិកជន ព្យាយាមអធិប្បាយលក្ខណៈព្រះយេស៊ូជាច្រើនកន្លែងដើម្បីតំរូវទៅតាមលក្ខណៈរបស់ព្រះសិរីអារ្យមេត្រី

*(នៅមានត)....*